ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ

- សំណុំរឿងព្រហ្មទណ្ឌលេខ ១១១៨

ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០

- សាលក្រមលេខ ០៦ "ញ" / ៤៩

ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

បន្ទាយមានជ័យ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបន្ទាយមានជ័យ

- បានបើកសវនាការជាសាធារណៈ នៅសាលសវនាការទី១ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ។
- កាលបរិច្ឆេទបើកសវនាការ ៖ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១។
- កាលបរិច្ឆេទប្រកាសសាលក្រម ៖ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១។

### ចៅក្រមជំនុំជម្រះ

- លោក- [redacted] ឋានៈចៅក្រម និងជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ឋានៈចៅក្រម និងជាចៅក្រមប្រឹក្សា
- លោក [redacted] ឋានៈចៅក្រម និងជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

- លោក [redacted] ឋានៈព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

- លោក [redacted] ឋានៈក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១១១៨ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] គឹមឡូវ ភេទប្រុស កើតឆ្នាំ១៩៩៦ សញ្ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតភូមិ[redacted] ខេត្តបាត់ដំបង អាសយដ្ឋានមុនពេលឃុំខ្លួនភូមិបាលិលេយ្យ២ សង្កាត់[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] គឹមពៅ "រស់" ម្ដាយឈ្មោះ [redacted] ជីតា ហៅ មុំ "រស់" នៅលីវ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦០២ ព្រទ.III "ខ"/២០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ ។

២. ឈ្មោះ [redacted] សុខហេង ភេទប្រុស កើតថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៩៨ សញ្ជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើតភូ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួននៅភូ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ថន "រស់" ម្ដាយឈ្មោះ [redacted] សារឿន "រស់" នៅលីវ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦០៣ ព្រទ.III "ខ"/២០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ ។



Scanned with CamScanner

*ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (ការកាប់គាស់ទម្លុះទម្លាយ)* ប្រព្រឹត្តនៅចំណុចភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដែលមានលោកស្រីមេធាវី [redacted] និងលោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងពីរ។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] ប៊ុនឡេង ភេទប្រុស កើតថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៨០ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើតភូមិបន្សាយត្រែង ស្រុកបាត់ដំបង ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្នភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ប៊ុនអេង "រស់" ម្តាយឈ្មោះ [redacted] សុខន "រស់" ប្រពន្ធឈ្មោះ [redacted] តេនា មានកូន ០៣នាក់ ជានីតិជន។

## ១. អង្គហេតុចោទប្រកាន់មានដូចតទៅ

កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ ម៉ោង ០១ និង ៣០ នាទីរំលងអធ្រាត្រ មានអំពើលួចស្ថានទម្ងន់ទោស (គាស់ឃ្លាំង) មួយបានកើតឡើង នៅចំណុចភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បង្កឡើងដោយជនល្មើសបីនាក់។ មុនកើតមានអំពើ លួច ដូចខាងលើនេះកើតឡើង គឺនៅម៉ោង ២១យប់ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ ជនរងគ្រោះឈ្មោះ [redacted] ប៊ុនឡេង ភេទប្រុស បានរៀបចំអីវ៉ាន់ទុកដាក់ និងបិទទ្វារឃ្លាំង ជាកន្លែងលក់ដូររបស់ខ្លួន ហើយបានទៅសម្រាកនៅផ្ទះក្បែរឃ្លាំងនោះដែរ។ លុះព្រឹកឡើងជនរងគ្រោះជាម្ចាស់បានមកបើកឃ្លាំងដើម្បីលក់ដូរធម្មតា ក៏ឃើញស្នាមគាស់ទ្វារឃ្លាំងរបស់ខ្លួន ហើយជនរងគ្រោះក៏បានចូលទៅមើលក្នុងឃ្លាំង ទើបដឹងថាបាត់ម៉ូតូមួយគ្រឿងម៉ាក ZOOMER-X ពណ៌ខ្មៅ សេរីឆ្នាំ ២០២០ ពាក់ផ្លាកលេខ បន្ទាយមានជ័យ 1U-0788 និងស្រាបៀកម្ពុជា ចំនួន៥៥កេះ។ ជនរងគ្រោះបានឆែកកាមេរ៉ាសុវត្ថិភាពមើល បានឃើញពួកចោរបីនាក់ធ្វើសកម្មភាពគាស់ឃ្លាំងរបស់ខ្លួន យកសម្ភារៈខាងលើ ហើយជនរងគ្រោះបានដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចនគរបាលឱ្យជួយចាត់វិធានការណ៍លើក្រុមជនល្មើស។ ក្រោយពីធ្វើការស្រាវជ្រាវ សមត្ថកិច្ចនគរបាលបានឃាត់ខ្លួនជនល្មើសចំនួនពីរនាក់ មានឈ្មោះ [redacted] គឹមឡូវ និងឈ្មោះ [redacted] សុខហេង និងដកហូតសម្ភារៈប្រគល់ឱ្យម្ចាស់ដើមវិញ ចំណែកជនល្មើសឈ្មោះ [redacted] រត់គេចខ្លួនបាត់។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១១៤៩ អ.យ.យ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។
- បានឃើញ ដីកាដំណោះស្រាយលេខ ៥២៨០ ៣ស.ព្រស-ខ-/២០ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ។
- បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខ ១៣០៦ ៣ស.ព្រជ-ក-/២០ ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ។

## ២. នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] គឹមឡូវ ភេទប្រុស បានឆ្លើយថា នៅយប់កើតហេតុ ខ្លួនបានខ្ចីម៉ូតូកង់បីពីឈ្មោះ [redacted] សុខហេង ភេទប្រុស ជិះទៅទិញថ្នាំញៀនដក់ ហើយក៏ជួបឈ្មោះ [redacted] នៅតាមផ្លូវ ពេលនោះគេបានពឹងខ្លួនឱ្យជួយដឹកស្រាបៀ ចាំគេឱ្យលុយ ៥០.០០០ (ប្រាំម៉ឺន) រៀល ខ្លួនក៏យល់ព្រម ដើម្បីបានលុយទិញថ្នាំញៀនដក់ ហើយខ្លួនបានបើកម៉ូតូកង់បីតាមពីក្រោយម៉ូតូឈ្មោះ ង៉ោល រហូតដល់ឃ្លាំងដាក់អីវ៉ាន់មួយ

នៅម្តុំផ្សារត្រី បន្ទាប់មកខ្លួន និងឈ្មោះ ង៉ោល នាំគ្នាជញ្ជូនស្រាបៀដាក់លើម៉ូតូកង់បី រួចហើយឈ្មោះ ង៉ោល ក៏ជិះម៉ូតូម៉ាក ZOOMER ចេញទៅមុន ខ្លួនបើកម៉ូតូកង់បីតាមក្រោយ ហើយបានយកទៅលក់នៅតូបចាប់ហួយ ២៤ម៉ោង ហើយឈ្មោះ ង៉ោល ក៏ដើរទៅនិយាយជាមួយនឹងម្ចាស់តូប រួចប្រាប់ខ្លួនឱ្យលើកស្រាបៀចុះ ខ្លួនក៏ដាក់ស្រាបៀចុះនៅទីនោះទាំងអស់ ហើយឈ្មោះ ង៉ោល ក៏ឱ្យលុយមកខ្លួនចំនួន ៥០.០០០ រៀល ពេលបានលុយខ្លួនក៏ជិះម៉ូតូត្រឡប់ទៅផ្ទះវិញ។ បន្ទាប់មកពេលខ្លួន និងឈ្មោះ [redacted] សុខហេង រៀបចំជក់ថ្នាំញៀន សមត្ថកិច្ចក៏មកចាប់ឃាត់ខ្លួនតែម្តង។ ចំពោះម៉ូតូ និងស្រាបៀរនោះ ខ្លួនមិនដឹងថា ជារបស់ឈ្មោះ ង៉ោល វាលួចគេទេ ព្រោះឈ្មោះ ង៉ោល ក៏មានម៉ូតូZOOMER ជិះដែរ។ ចំណែកស្រាបៀ ពេលខ្លួនទៅជញ្ជូនដាក់ម៉ូតូកង់បី ពុំឃើញមានទ្វារបិទទេ មានបាំងតែតង់បន្តិចប៉ុណ្ណោះ។

- ជនជាប់ចោទឈ្មោះ [redacted] សុខហេង ភេទប្រុស បានឆ្លើយថា នៅយប់កើតហេតុ ខ្លួនបានខ្ចីម៉ូតូកង់បីពីឈ្មោះ តឿ ភេទប្រុស ជិះទៅរកទិញស៊្តីហ្វូប ពេលជិះទៅដល់ផ្ទះឈ្មោះ [redacted] គីមឡូវ ខ្លួនក៏សួរគាត់ថា មានលុយទិញថ្នាំញៀនជក់អត់ ពេលនោះឈ្មោះ ឡូវ ក៏ខ្ចីម៉ូតូនោះជិះទៅទិញថ្នាំញៀន ហើយឈ្មោះ ឡូវ ត្រឡប់មកវិញ ក៏ឃើញឈ្មោះ ង៉ោល ជិះម៉ូតូម៉ាក ZOOMER-X ពណ៌ខ្មៅ មកតាមក្រោយដែរ បន្ទាប់មកឈ្មោះ ង៉ោល បានសុំផ្ញើម៉ូតូនោះនៅនឹងផ្ទះរបស់ខ្លួនមួយយប់ ដោយឃើញឈ្មោះ ង៉ោល និងឈ្មោះ ឡូវ គាត់រាប់អានគ្នាស្និទ្ធ ខ្លួនក៏យល់ព្រម ពេលឃើញម៉ូតូគ្មានកូនសោរ ក៏សួរថា ម៉េចម៉ូតូអត់សោរ ឈ្មោះ ង៉ោល ឆ្លើយថាជ្រុះបាត់ហើយ ចាំផ្តាច់ខ្សែភ្លើងផង និងប្រាប់ឱ្យខ្លួនដោះផ្លាកលេខម៉ូតូចេញ ខ្លួនក៏ធ្វើតាមគាត់ប្រាប់។ បន្ទាប់មកពេលខ្លួន និងឈ្មោះ ឡូវ រៀបចំជក់ថ្នាំញៀននៅនឹងផ្ទះឈ្មោះ ឡូវ សមត្ថកិច្ចក៏មកចាប់ឃាត់ខ្លួនតែម្តង។ ខ្លួនមិនបានចូលរួមធ្វើសកម្មភាពលួចជាមួយពួកគេទេ ប៉ុន្តែពេលសមត្ថកិច្ចសួរចម្លើយ គេឱ្យខ្លួនមើលរូបភាពក្នុងកាមេរ៉ាសុវត្ថិភាព បានឃើញឈ្មោះ ង៉ោល និងឈ្មោះ ឡូវ ជញ្ជូនស្រាបៀពីខាងក្នុងមកក្រៅ តែមិនសូវច្បាយទេ តែមិនឃើញជញ្ជូនដាក់ម៉ូតូកង់បីទេ។

- តាមអំណានកំណត់ហេតុទទួលបណ្តឹងឈ្មោះ [redacted] ប៊ុនឡុង ភេទប្រុស នៅអធិការនគរបាលក្រុងប៉ោយប៉ែត ប្តឹងថា នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ ម៉ោង ០៩យប់ ខ្លួនបានបិទទ្វារឃ្លាំងដែលខ្លួនលក់អីវ៉ាន់ចាប់ហួយ ហើយបានទៅដេកផ្ទះដែលនៅជិតនោះដែរ។ ព្រឹកឡើងខ្លួនទៅបើកទ្វារឃ្លាំងដើម្បីលក់ដូរ ក៏ឃើញទ្វារឃ្លាំងត្រូវចោរគាស់ ពេលខ្លួនចូលទៅមើលក្នុងឃ្លាំង ស្រាប់តែបាត់ម៉ូតូម៉ាក ZOOMER-X ពណ៌ខ្មៅ ពាក់ផ្លាកលេខ បន្ទាយមានជ័យ 1U-0788 និងស្រាបៀកម្ពុជាចំនួន ៥៥កេះ បន្ទាប់មកពេលខ្លួនទៅឆែកមើលកាមេរ៉ាសុវត្ថិភាព ឃើញចោរបីនាក់ ធ្វើសកម្មភាពគាស់ឃ្លាំង ខ្លួនក៏ទៅដាក់ពាក្យបណ្តឹងនៅសមត្ថកិច្ច។

- តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន បន្ទាប់ពីឆ្លងកាត់ការសួរដេញដោលនាពេលសវនាការ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] គីមឡូវ និងឈ្មោះ [redacted] សុខហេង ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។ ចំពោះការឆ្លើយបដិសេធរបស់ជនជាប់ចោទ គ្រាន់តែជាចម្លើយដោះសារប៉ុណ្ណោះ ជាក់ស្តែងជនជាប់ចោទឈ្មោះ [redacted] គីមឡូវ គឺបានជិះម៉ូតូកង់បីទៅដឹកស្រាបៀពីកន្លែងកើតហេតុយកទៅលក់នៅហាង ២៤ម៉ោង ចំណែកជនជាប់ចោទឈ្មោះ [redacted] សុខហេង បានឆ្លើយទទួលស្គាល់ថា ខ្លួនពិតជាបានយកម៉ូតូម៉ាក ZOOMER-X ទៅលាក់ទុកនៅផ្ទះរបស់ខ្លួនមែន។ បើយោងតាមរបាយការណ៍សមត្ថកិច្ចបានបញ្ជាក់ថា ក្រោយពីសមត្ថកិច្ចធ្វើការស្រាវជ្រាវ និងពិនិត្យមើលកាមេរ៉ាសុវត្ថិភាពនៅកន្លែងកើតហេតុ បានឃើញចោរដែលគាស់ឃ្លាំង មានគ្នាបីនាក់ ទើបសមត្ថកិច្ចឈានដល់ការចាប់ជនទាំងពីរនាក់នេះ ហើយបានដកហូតម៉ូតូម៉ាក ZOOMER-X និងស្រាបៀប្រគល់ឱ្យទៅម្ចាស់ដើមវិញ។ តាមការអំណានកំណត់ហេតុបណ្តឹង និងភស្តុតាងនានាក្នុងសំណុំរឿង បង្ហាញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន អំពើរបស់ជនជាប់ចោទ



Scanned with CamScanner

នេះ បានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម។ តំណាងអយ្យការសុំរក្សាបទចោទប្រកាន់ដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

- មេធាវីការពារជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋានការពារៈ បន្ទាប់ពីបានស្តាប់ការសួរដេញដោល និងការអានកំណត់ហេតុបណ្តឹងរបស់ដើមបណ្តឹង ឃើញថា កូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការទេ តាមការសួរដេញដោល កូនក្តីខ្លួនគ្រាន់តែបានដឹកជញ្ជូនស្រាបៀ ដោយទទួលបានកម្រៃប្រាំម៉ឺនរៀល ប៉ុណ្ណោះ។ ព្រោះតែជីវភាពខ្វះខាត ទើបកូនក្តីខ្លួនដឹកឱ្យតែម្តងទៅ កូនក្តីខ្លួនមិនបានចូលរួមក្នុងសកម្មភាពគាស់ឃ្លាំងលួចយកម៉ូតូមួយគ្រឿង និងស្រាបៀទាំងនេះទេ។ ក្នុងនាមជាមេធាវីការពារជនជាប់ចោទស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់នេះ។

- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] គឹមឡូវៈ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសផង។
- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខហេងៈ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសផង។

## តុលាការ

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានកំណត់ហេតុបណ្តឹង
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យកស្តុតាង និងឯកសារនានាក្នុងសំណុំរឿង

## ៣. សំអាងហេតុ

១. ជនជាប់ចោទឈ្មោះ [redacted] គឹមឡូវ ភេទប្រុស កើតឆ្នាំ១៩៩៦ និងឈ្មោះ [redacted] សុខហេង ភេទប្រុស កើតឆ្នាំ១៩៩៨ ត្រូវបានចៅក្រមស៊ើបសួរប្តឹងចោទប្រកាន់បញ្ជូនមកជំនុំជម្រះ តាមដីកាដំណោះស្រាយលេខ ៥២៨០ ពស.ព្រស"ខ"/២០ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ *ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (ការកាប់គាស់ទម្លុះទម្លាយ)* ប្រព្រឹត្តនៅភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២. ជនជាប់ចោទឈ្មោះ [redacted] គឹមឡូវៈ

- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] គឹមឡូវ បានឆ្លើយនាពេលសវនាការថា នៅយប់ថ្ងៃកើតហេតុ ខ្លួនបានខ្ចីម៉ូតូកង់បីពីឈ្មោះ [redacted] សុខហេង ទៅទិញថ្នាំញៀនជក់ ក៏ជួបនឹងឈ្មោះ ង៉ោល នៅតាមផ្លូវ ហើយឈ្មោះ ង៉ោល បានពឹងខ្លួនឱ្យជួយដឹកស្រាបៀនៅឃ្លាំងដាក់អីវ៉ាន់មួយ នៅម្តុំផ្សាររាត្រី ដោយសន្យាឱ្យលុយ ៥០.០០០ (ប្រាំម៉ឺន) រៀល ខ្លួនក៏យល់ព្រម។ បន្ទាប់មកខ្លួន និងឈ្មោះ ង៉ោល នាំគ្នាជញ្ជូនស្រាបៀដាក់ម៉ូតូកង់បី ដឹកទៅលក់នៅតូបចាប់ហួយ ២៤ ម៉ោងហើយក៏ទំលាក់ស្រាបៀចុះនៅទីនោះទាំងអស់ ហើយខ្លួនបានលុយចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ក៏ត្រឡប់ទៅផ្ទះវិញ។ ពេលទៅដល់ផ្ទះស្រាប់តែឃើញឈ្មោះ ង៉ោល បានជិះម៉ូតូZOOMER មកដល់ដែរ ហើយបានសុំផ្ញើម៉ូតូនោះទុកនៅផ្ទះរបស់ឈ្មោះ ហេង មួយយប់។ ពេលឈ្មោះ ហេង ជិះម៉ូតូនោះទៅទុកនៅផ្ទះរបស់គេរួច ទើបដើរមកជក់ថ្នាំញៀននៅផ្ទះរបស់ខ្លួនវិញ ពេលជក់ថ្នាំញៀនបានបន្តិច សមត្ថកិច្ចក៏មកចាប់ឃាត់ខ្លួនតែម្តង។



Scanned with CamScanner

- ជនជាប់ចោទ បានបញ្ជាក់ថាខ្លួនដឹកស្រាបៀ ដោយយកកម្រៃ ៥០.០០០ (ប្រាំម៉ឺន) រៀល ពីឈ្មោះ ង៉ោល នៅម៉ោង ២ ជិត ៣ ទាបភ្លឺ ដើម្បីយកទៅលក់ ប៉ុន្តែជនជាប់ចោទមិនអាចបញ្ជាក់ ពីមូលហេតុដែលលក់ទំនិញឱ្យគេពេលទាបភ្លឺនោះទេ ម្យ៉ាងវិញទៀតជនជាប់ចោទ មានមុខរបរជាអ្នករើសអេតចាយនៅពេលយប់ ដូច្នេះមិនមានហេតុផលដែលយប់ថ្ងៃកើតហេតុ ជនជាប់ចោទបានខ្ចីម៉ូតូកង់បីពីអ្នកដទៃមកជិះឡើយ។ តាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ ណៃ ប៊ុនឡុង បានបញ្ជាក់ថា នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ ខ្លួនបានមកដល់ឃ្លាំងលក់អីវ៉ាន់ បានឃើញទ្វារឃ្លាំងត្រូវបានគាស់ បន្ទាប់មកខ្លួនបានមើលកាមេរ៉ាសុវត្ថិភាពឃើញថា ក្រុមរបស់ជនជាប់ចោទមានគ្នាចំនួន៣នាក់ ហើយបានធ្វើការដឹកជញ្ជូនស្រាបៀកម្ពុជាចំនួន ៥៥កេះ ដាក់ម៉ូតូកង់បី និងយកម៉ូតូម៉ាកហុងដា ស៊ូមីអ៊ិច ផលិតឆ្នាំ២០២០ ពណ៌ខ្មៅ លេខតួនិងម៉ាស៊ីន 5104280 ពាក់ផ្លាកលេខបន្ទាយមានជ័យ 1U-0788 ពីក្នុងឃ្លាំងចេញមក។ ដូច្នេះអាចឱ្យតុលាការជឿជាក់បានថា ជនជាប់ចោទពិតជាបានចូលគាស់ទ្វារលួចស្រាបៀ និងម៉ូតូជាមួយឈ្មោះ ង៉ោល ពិតប្រាកដមែន។

៣. ជនជាប់ចោទឈ្មោះ [redacted] សុខហេង៖

- តាមចម្លើយរបស់ជនជាប់ចោទបានឆ្លើយបដិសេធនាពេលសវនាការថា ខ្លួនមិនបានចូលរួមធ្វើសកម្មភាពលួចជាមួយពួកគេទេ នៅយប់ថ្ងៃកើតហេតុ ខ្លួនបានខ្ចីម៉ូតូកង់បីពីឈ្មោះ តឿ ភេទប្រុស ជិះទៅទិញថ្នាំញៀនជក់ ពេលដល់ផ្ទះឈ្មោះ [redacted] គីមឡូវ ខ្លួនក៏សួរវាថា មានលុយទិញថ្នាំញៀនជក់អត់ ហើយវាក៏ជិះម៉ូតូនោះទៅទិញថ្នាំញៀន។ ពេលឈ្មោះ ឡូវ ត្រឡប់មកវិញ ក៏ឃើញឈ្មោះ ង៉ោល ជិះម៉ូតូម៉ាកZOOMER-X ពណ៌ខ្មៅ មកដល់ដែរ ហើយបានសុំផ្ញើម៉ូតូនោះនៅផ្ទះរបស់ខ្លួនមួយយប់ ដោយឃើញឈ្មោះ ង៉ោល រាប់អានគ្នាស្និទ្ធជាមួយឈ្មោះ ឡូវ ខ្លួនក៏យល់ព្រម។ ពេលខ្លួនឃើញម៉ូតូគ្មានកូនសោរ ក៏សួរថា ម៉េចម៉ូតូអត់សោរ ឈ្មោះ ង៉ោល ឆ្លើយថាជ្រុះបាត់ហើយ ចាំផ្តាច់ខ្សែភ្លើងពន្លត់ទៅ និងប្រាប់ឱ្យខ្លួនដោះផ្លាកលេខម៉ូតូនោះចេញផង។

- ជនជាប់ចោទបានបដិសេធថា ខ្លួនមិនបានចូលរួមធ្វើសកម្មភាពលួចជាមួយពួកគេទេ ដោយខ្លួននៅផ្ទះរបស់ឈ្មោះ [redacted] គីមឡូវ រហូត ចម្លើយបដិសេធនេះមិនអាចជឿជាក់បានឡើយ គឺគ្រាន់តែជាចម្លើយដោះសារគេចវេសពីការទទួលខុសត្រូវតែប៉ុណ្ណោះ ជាក់ស្តែងនៅយប់ថ្ងៃកើតហេតុ ជនជាប់ចោទបានទៅខ្ចីម៉ូតូកង់បី ពីឈ្មោះ តឿ ហើយទៅជួបឈ្មោះ [redacted] គីមឡូវ បន្ទាប់ពីធ្វើសកម្មភាពរួច ជនជាប់ចោទបានដោះផ្លាកលេខម៉ូតូ Zoomer-X ពណ៌ខ្មៅ និងបានផ្តាច់ខ្សែភ្លើងពន្លត់ ចម្លើយនេះមានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ដើមបណ្តឹង ដែលបានបញ្ជាក់ថា អ្នកចូលគាស់ឃ្លាំងរបស់ខ្លួន មានគ្នាបីនាក់។ តាមចម្លើយនេះអាចសបញ្ជាក់បានថា ជនជាប់ចោទពិតជាបានចូលរួមប្រព្រឹត្តអំពើលួច ដោយគាស់ឃ្លាំងជាមួយឈ្មោះ [redacted] គីមឡូវ និងឈ្មោះ ង៉ោល ប្រាកដមែន។

៤. តាមចម្លើយរបស់ជនជាប់ចោទ, កំណត់ហេតុទទួលបណ្តឹង និងភស្តុតាងនានាក្នុងសំណុំរឿង អាចបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] គីមឡូវ ភេទប្រុស និងឈ្មោះ [redacted] សុខហេង ភេទប្រុស ពិតជាបានចូលគាស់ឃ្លាំង លួចស្រាបៀកម្ពុជា ចំនួន៥៥កេះ និងម៉ូតូម៉ាក ZOOMER-X ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២០ ពាក់ផ្លាកលេខ បន្ទាយមានជ័យ 1U-0788 របស់ឈ្មោះ ណៃ ប៊ុនឡេង ពិតប្រាកដមែន កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០។

៥. អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] គីមឡូវ ភេទប្រុស និងឈ្មោះ [redacted] សុខហេង ភេទប្រុស ដែលបានគាស់ឃ្លាំងលួចយកទ្រព្យសម្បត្តិរបស់អ្នកដទៃ នៅវេលាម៉ោង ២ ទៅ ៣ ទាបភ្លឺ គឺស្តែងឱ្យឃើញអំពីចេតនាទុច្ចរិត ពិតប្រាកដ របស់ជនជាប់ចោទក្នុងការប្រព្រឹត្តអំពើល្មើសដែលត្រូវបានចោទប្រកាន់។



Scanned with CamScanner

៦. មានជាតុផ្សំនៃបទល្មើស និងភស្តុតាង នៃពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] គីមឡូវ ភេទប្រុស និងឈ្មោះ [redacted] សុខហេង ភេទប្រុស ពីបទ *លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (ការកាប់គាស់ទម្លុះទម្លាយ)* ប្រព្រឹត្តនៅភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ គប្បីតុលាការប្រកាសពី ពិរុទ្ធភាព និងប្រកាសទោសលើជនជាប់ចោទតាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៧. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន រក្សាបទចោទប្រកាន់ដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ គប្បីតុលាការលើកមកពិចារណា។

៨. មេធាវីការពារជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋានការពារៈ សុំឱ្យតុលាការសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទប្រកាន់ ដោយមូលហេតុកូនក្តីខ្លួនមិនបានប្រព្រឹត្តទេ។ គប្បីតុលាការលើកមកពិចារណា។

៩. ជនជាប់ចោទឈ្មោះ [redacted] គីមឡូវ ភេទប្រុស និងឈ្មោះ [redacted] សុខហេង ភេទប្រុស បានថ្លែងសេចក្តីចុងក្រោយ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង។ តុលាការនឹងលើកមកពិចារណា។

១០. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនឡេង ភេទប្រុស ពុំបានចូលមកតាំងខ្លួនជាដើមបណ្តឹងនៅជំណាក់កាលស៊ើបសួរ និងជំណាក់កាលជំនុំជម្រះ គប្បីតុលាការមិនលើកមកពិចារណាអំពីសំណងឡើយ។

១១. តាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៥២០ អ.យ.ឃ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ បានដកហូតមាន ការបូបស្ពាយចំហៀង ចំនួន០១ (សភាពចាស់), កូនសោរឡាន ចំនួន០២ (ម៉ាក Toyota), កូនកន្ត្រៃដងលឿង ចំនួន០១, ដង្កាប់ដងលឿង ចំនួន០១, ទុលវិស ចំនួន០២ និងកូនសោរផ្ទះមួយចង្កោម (ជារបស់ឈ្មោះ ង៉ោល) ឃើញថាវត្ថុតាងនេះ ជាវត្ថុដែលជនជាប់ចោទបានយកមកប្រព្រឹត្តបទល្មើស គប្បីសម្រេចប្រកាសទោសបន្ថែមរឹបអូស យោងតាមបញ្ញត្តិមាត្រា ៥៣ និងមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

## ៤. ហេតុដូច្នេះ សម្រេច

### ១. ផ្តន្ទាទោស

១.១. ឈ្មោះ [redacted] **គីមឡូវ** ភេទប្រុស កើតឆ្នាំ១៩៩៦ សញ្ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតភូ[redacted] ខេត្តបាត់ដំបង អាសយដ្ឋានមុនពេលឃុំខ្លួនភូមិ [redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] គីមពៅ "រស់" ម្តាយឈ្មោះ [redacted] ធីតា ហៅ មុំ "រស់" នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

**កំណត់ដាក់ពន្ធនាគាររយៈពេល ០៣ (បី) ឆ្នាំ** ពីបទ ***លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (ការកាប់គាស់ទម្លុះទម្លាយ)*** ប្រព្រឹត្តនៅភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

១.២. ឈ្មោះ [redacted] **សុខហេង** ភេទប្រុស កើតថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៩៨ សញ្ជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើត[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួននៅភូមិ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ថន "រស់" ម្តាយឈ្មោះ [redacted] សារឿន "រស់" នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។



Scanned with CamScanner

កំណត់ដាក់ពន្ធនាគាររយៈពេល ០៣ (បី) ឆ្នាំ ពីបទ *លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា (ការកាប់គាស់ទម្លុះទម្លាយ)* ប្រព្រឹត្តនៅភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

**២. រឹបអូសវត្ថុចាប់យក**

២.១. ការបូបស្ពាយចំហៀង ចំនួន០១ (សភាពចាស់) ជារបស់ឈ្មោះ **ង៉ោល** ។

២.២. កូនសោរឡាន ចំនួន០២ (ម៉ាកToyota) ជារបស់ឈ្មោះ **ង៉ោល** ។

២.៣. កូនកន្ត្រៃដងលឿង ចំនួន០១ ជារបស់ឈ្មោះ **ង៉ោល** ។

២.៤. ដង្កាប់ដងលឿង ចំនួន០១ ជារបស់ឈ្មោះ **ង៉ោល** ។

២.៥. ទុលវិស ចំនួន០២ ជារបស់ឈ្មោះ **ង៉ោល** ។

២.៦. កូនសោរផ្ទះមួយចង្កោម ជារបស់ឈ្មោះ **ង៉ោល** ។

*"វត្ថុចាប់យកនេះត្រូវបានរក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាល សាលាដំបូងខេត្តបន្ទាយមានជ័យ តាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៥២០ អ.យ.យ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០។"*

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **គីមឡូច** ភេទប្រុស និងឈ្មោះ [redacted] **សុខហេង** ភេទប្រុស។

*ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃចន្ទ ២កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
បន្ទាយមានជ័យ, ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១
**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
បន្ទាយមានជ័យ,ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២១
ក្រឡាបញ្ជី

[redacted]